## ខ) ព្រឹទ្ធសភា[១៣]



### I) ការបង្កើតព្រឹទ្ធសភាៈ

ជាដំបូង ព្រឹទ្ធសភាមិនទាន់កើតមាននៅឡើយ នៅពេលដែលរដ្ឋធម្មនុញ្ញកម្ពុជាចូលជាធរមាន នៅក្នុងឆ្នាំ១៩៩៣ ។ ប៉ុន្តែ ព្រឹទ្ធសភា ត្រូវបានបង្កើតឡើងនៅក្រោយការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញក្នុងឆ្នាំ ១៩៩៩ ។

### II) ការបោះឆ្នោតជ្រើសរើសព្រឹទ្ធសមាជិកៈ

សម្រាប់**អាណត្តិ ៥ឆ្នាំ**ដំបូង សមាជិកព្រឹទ្ធសភាមិនត្រូវបានបោះឆ្នោតជ្រើសតាំងឡើយ គឺគ្រាន់តែត្រូវបាន**តែងតាំង**ដោយព្រះមហាក្សត្រ ។ (មាត្រា ១៥៧ II CC)

បន្ទាប់ពីផុតអាណត្តិទី១នេះទៅ គឺមានតែព្រឹទ្ធសមាជិកចំនួន ២នាក់ ប៉ុណ្ណោះ ដែលនឹងត្រូវតែងតាំងដោយព្រះមហាក្សត្រ និងសមាជិកព្រឹទ្ធភាភាគច្រើននឹងត្រូវជ្រើសរើសដោយ**ការបោះឆ្នោតអសកល** (មាត្រា៩៩ និង ១០០ CC) សំរាប់**អាណត្តិ៦ឆ្នាំ** (មាត្រា១០២ I CC )។ នោះមានន័យថា ពួកគេនឹងមិនត្រូវបានបោះឆ្នោតជ្រើសរើសដោយផ្ទាល់ដោយប្រជាពលរដ្ឋកម្ពុជាឡើយ គឺដោយក្រុមដែលពាក់ព័ន្ធផ្សេងៗ ។ សេចក្តីពិស្តារនៅមិនទាន់ច្បាស់លាស់នៅឡើយ អាស្រ័យដោយច្បាប់បោះឆ្នោតព្រឹទ្ធសភាដែលចាំបាច់ នៅមិនទាន់បានពិភាក្សា និងអនុម័តនៅឡើយ ។ ច្បាប់បែបនេះ ត្រូវស្របទៅនឹង**គោលគំនិតជាមូលដ្ឋាននៃពហុភាព និងការតំណាង**ដូចដែលបានចារឹកនៅក្នុងរដ្ឋធម្មនុញ្ញកម្ពុជា ។ ដើម្បីព្រាងច្បាប់បែបនេះ អ្នកបង្កើតច្បាប់គួរតែចងចាំថា ស្ថាប័ននីតិបញ្ញតិទីពីរបែបនេះ (សូមមើលគោលការណ៍នៃទ្វិសភា bi-Cameralism) ត្រូវដើរតួនាទីសំខាន់មួយក្នុងការថ្លឹងថ្លែងនូវវិវាទនយោបាយនានា និងជាដំបូង ដើម្បីផ្តល់នូវការតំណាងឱ្យកាន់តែទូលាយចំពោះដំណើរការបង្កើតច្បាប់ ។

### III) សិទ្ធិរបស់ព្រឹទ្ធសមាជិកៈ

ព្រឹទ្ធសសមាជិក មានសិទ្ធិស្មើគ្នាក្នុងការទទួល**អភ័យឯកសិទ្ធិ** ដូចជាសមាជិករដ្ឋសភាដែរ (មាត្រា ១០៤ CC)[១៤] ។ នោះមានន័យថា ពួកគេនឹងមិនត្រូវទទួលការផ្តន្ទាទោសចំពោះការបញ្ចេញមតិនៅក្នុងការបំពេញភារកិច្ចរបស់ខ្លួនឡើយ ។

[១៣] ចំពោះសេចក្តីពិស្តារបន្ថែម សូមមើលអ៊ិនធឺណិតៈ www. khmersenate.org
[១៤] ព័តិមានលំអិតសូមមើលទំព័រទី ៣៣

## IV) មុខងារ និងតួនាទីរបស់ព្រឹទ្ធសភា:

ផ្ទុយពីរដ្ឋសភា ព្រឹទ្ធសភាមិនមាន**អំណាចពិតប្រាកដដើម្បីធ្វើច្បាប់ ឬដើម្បីជ្រើសតាំង និងគ្រប់គ្រងរដ្ឋាភិបាល**ឡើយ។ ព្រឹទ្ធសភាអាចផ្តួចផ្តើមគំនិតឱ្យមានច្បាប់ (មាត្រា៩១ I CC) ប៉ុន្តែខ្លួនមិនអាចដេញដោលសួរ ចោទប្រកាន់ ឬបណ្តេញរដ្ឋាភិបាល ឬសមាជិករបស់គេចោលឡើយ ។

ព្រឹទ្ធសភា មាន**តួនាទីជាទីប្រឹក្សា**ច្រើនជាង ហើយអាចផ្តល់ជា**អនុសាសន៍** ផ្ទុយពីរដ្ឋសភាដែលមានអំណាចចុងក្រោយក្នុងការបង្កើត និងអនុម័តច្បាប់ (មាត្រា១១៣ VII CC: ប្រសិនបើរដ្ឋសភាពិនិត្យមើលពង្រាងច្បាប់ជាលើកទីពីរ បន្ទាប់ពីព្រឹទ្ធសភាបានអំពាវនាវឱ្យមានការកែសម្រួល គឺរដ្ឋសភាខ្លួនឯងជាអ្នកសម្រេចចុងក្រោយ) ។

ព្រឹទ្ធសភារៀបចំ**សម័យប្រជុំរបស់ខ្លួនជាសាធារណៈ** (មាត្រា១១១ I CC) និង**ពីរដងមួយឆ្នាំ** (ដែលសម័យប្រជុំនីមួយៗមានរយៈពេលបីខែ)ដូចរដ្ឋសភាដែរ ។

រចនាសម្ព័ន្ធ និងទម្រង់ការ តិចឬច្រើន ប្រហាក់ប្រហែលនឹងរចនាសម្ព័ន្ធ និងទម្រង់ការរបស់រដ្ឋសភាដែរ។ ព្រឹទ្ធសភា ក៏មាន**ប្រធាន អគ្គលេខាធិការ គណៈកម្មាធិការអចិន្ត្រៃយ៍មួយ** និង **គណៈកម្មការផ្សេងៗ** ដែរ ។

ព្រឹទ្ធសភាក៏មានបទបញ្ជាផ្ទៃក្នុងរបស់ខ្លួនដែរ[១៥] ។

[១៥] ឯកសារស្តីអំពីបទបញ្ជាទាំងនេះ អាចរកឃើញនៅក្នុងគេហទំព័រអ៊ិនធឺណិតរបស់ព្រឹទ្ធសភា: www.khmersenate.org

## ? សំនួរសិក្សាទី ៤

ក) ចូរអានរដ្ឋធម្មនុញ្ញកម្ពុជា និងរៀបរាប់អំពីដំណាក់កាលដើម្បីបង្កើតរដ្ឋាភិបាលថ្មី បន្ទាប់ពីការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រមក!

ខ) ប្រសិនណា មតិភាគច្រើន ២/៣ នៅក្នុងសភា មិនអាចដោះស្រាយនយោបាយទាល់ច្រកបាន តើអ្នកគិតថាគួរតែធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញត្រង់ចំនុចណា ដើម្បីដោះស្រាយភាពទាល់ច្រកនោះ?

## ? សំនួរសិក្សាទី ៥

លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន មិនចង់ធ្វើការសំរុះសំរួលជាមួយនឹង "សម្ព័ន្ធភាពអ្នកប្រជាធិបតេយ្យ" ដែលទើបតែបង្កើតឡើង ថ្មីៗនេះដោយគណបក្សហ្វុនស៊ិនប៉ិច និង សមរង្ស៊ី ។

ក) គាត់និយាយថា គណបក្សហ្វុនស៊ិនប៉ិច និង សមរង្ស៊ី ទី១ មិនអាចឈ្នះឈ្នោះនៅពេលបោះឆ្នោតជាពីរគណបក្សផ្សេងគ្នា ហើយនៅពេលក្រោយបោះឆ្នោតមករួបរួមគ្នាជាបក្សតែមួយវិញ ដើម្បីធ្វើការចរចាបង្កើតរដ្ឋាភិបាលថ្មីមួយនោះទេ ។ លោកមានប្រសាសន៍ថា ករណីនេះផ្ទុយនឹងរដ្ឋធម្មនុញ្ញ ។

តើករណីនេះត្រូវ ឬខុស? សូមផ្តល់មូលហេតុចំពោះគំនិតរបស់អ្នកផង និងបញ្ជាក់អំពីមាត្រាដែលពាក់ព័ន្ធផង!

ខ) មន្ត្រីខ្លះនៃគណបក្សប្រជាជននិយាយថា ប្រទេសកម្ពុជានឹងមិនអាចក្លាយជាប្រទេសប្រជាធិបតេយ្យបានទេ ប្រសិនណាមិនមានគណបក្សប្រឆាំងនៅក្នុងរដ្ឋសភា ។ វាអាចនឹងផ្ទុយនឹងរដ្ឋធម្មនុញ្ញ ប្រសិនបើគណបក្សទាំងបី (ប្រជាជន, ហ្វុនស៊ិនប៉ិច និងសមរង្ស៊ី) បង្កើតរដ្ឋាភិបាលចំរុះមួយ ។

តើករណីនេះត្រូវ ឬខុស? សូមផ្តល់មូលហេតុចំពោះគំនិតរបស់អ្នកផង និងបញ្ជាក់អំពីមាត្រាដែលពាក់ព័ន្ធផង!

## ? សំនួរសិក្សាទី ៦

ចូរអានអត្ថបទសង្ខេបដែលដកស្រង់ចេញពីសារពតិមាន The Cambodian Daily ចេញផ្សាយថ្ងៃទី ២៦ ខែមិថុនា ឆ្នាំ ២០០២ ដោយយកចិត្តទុកដាក់ ។

ក្នុងចំណោមសមាជិកសភាមួយចំនួន លោក សុន ឆៃ កំពុងតែអំពាវនាវសុំការគាំទ្រពីសមាជិកសភាដទៃទៀត ក្នុងការបង្កើតគណៈកម្មការថ្មីមួយរបស់រដ្ឋសភា ដែលគេហៅថាៈ "គណៈកម្មការព្រំដែនឯករាជ្យ" ។

ហេតុផលគឺថា សមាជិកសភាចង់ដឹងថា តើរដ្ឋាភិបាលបានធ្វើអ្វីខ្លះហើយអំពីបញ្ហាព្រំដែន ប៉ុន្តែមកដល់ពេលនេះគេមិនទាន់មានឯកសារដែលពាក់ព័ន្ធនឹងបញ្ហាព្រំដែននៅឡើយទេ ពីព្រោះ គណៈកម្មការរួម ស្តីពីព្រំដែននៃក្រុមប្រឹក្សាគណៈរដ្ឋមន្ត្រី មិនបានចែករំលែកព័ត៌មានស្តីអំពីបញ្ហាព្រំដែនទេ ។

ចំពោះការពិភាក្សាលើបញ្ហាអន្តោប្រវេសន៍ខុសច្បាប់មករស់នៅលើទឹកដីកម្ពុជា សមាជិកបានអញ្ជើញ លោក ស ខេង សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដែលជាអ្នកបានទទួលសំបុត្រមួយពីលោក កែវ រេមី ដែលបានធ្វើការរិះគន់រដ្ឋាភិបាលដែលមិនបានធ្វើការទប់ស្កាត់ឱ្យបានតឹងរ៉ឹងចំពោះអន្តោប្រវេសន៍ខុសច្បាប់ ។

ក) តើមានគណៈកម្មការប៉ុន្មាននៅក្នុងរដ្ឋសភា? សូមកុំភ្លេចបញ្ជាក់អំពីមាត្រាដែលពាក់ព័ន្ធ!

ខ) តើសមាជិកសភាអាចបង្កើតគណៈកម្មការថ្មីដែលហៅថា "គណៈកម្មការព្រំដែនឯករាជ្យ" បានដែរឬទេ? សូមកុំគ្រាន់តែឆ្លើយ "អាច" ឬ "មិនអាច" ប៉ុន្តែសូមផ្តល់នូវហេតុផលចំពោះគំនិតរបស់អ្នក និងបញ្ជាក់អំពីមាត្រាដែលពាក់ព័ន្ធផង!